ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រាមួយ .-**

មាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៣០ .- ថ្មី**

កម្ពស់អគារនៅទីក្រុង ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានតំបន់ ប្រភេទអគារ ទំហំដីឡូត៍ ទំហំទទឹងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលសំណង់នោះតាំងនៅ និងលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ភូមិសាស្ត្រ វប្បធម៌ ជាសុកភាព សុខភាព និងសោភណភាព ស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែងរបស់ខ្លួន និងអនុវត្តតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម៖

១- វិធីសាស្ត្រទី១ : ការកំណត់កម្ពស់ជាម៉ែត្រ ឬ

- អគារកម្ពស់ទាប ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី១១
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ។

២- វិធីសាស្ត្រទី២ : ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ឬ

- ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ដូចមានចែងនៅក្នុងមាត្រា២២ មាត្រា២៦ និងមាត្រា២៨ នៃអនុក្រឹត្យនេះ។

៣- វិធីសាស្ត្រទី៣ : ការកំណត់កម្ពស់តាមប្លង់ទ្រេត ឬ

- អគារកម្ពស់ទាប ត្រូវបានអនុវត្តក្នុងករណីដែលទំហំទទឹងផ្លូវតូចជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ ដោយកម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងឆ្លាគម្លាត ស្មើនឹងចំនួន (ក)
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងឆ្លាគម្លាត ស្មើនឹងចំនួន (ខ)
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងឆ្លាគម្លាត ស្មើនឹងចំនួន (គ)។

៤- វិធីសាស្ត្រទី៤ : ការកំណត់កម្ពស់អគារ ដោយប្រើប្រាស់វិធីសាស្ត្រខាងលើពីរឬបីរួមគ្នា។

កម្ពស់អតិបរមានិងអប្បបរមាតាមជាន់នីមួយៗនៃអគារ ត្រូវកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ស្របទៅតាមប្រភេទនៃការប្រើប្រាស់អគារ និងតាមទីតាំងភូមិសាស្ត្រ។ ទោះជាយ៉ាងណាកម្ពស់អគារអប្បបរមាសម្រាប់មួយជាន់ៗកំណត់ត្រឹម២,៨ម៉ែត្រ សម្រាប់អគារស្នាក់នៅ។

ប្លង់កម្ពស់អគារនៃរាជធានី និងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ចំនួន (ក) (ខ) និង(គ) នឹងត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ការកំណត់កម្ពស់នៃអគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ ._ ថ្មី**

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវមានគ្រប់គ្រាន់តាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ និងទីតាំងសាធារណៈ។

ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អគារលំនៅឋានរួមមាន៖

| | | |
|---|---|---|
| - លំនៅឋានដាច់(ភូមិគ្រឹះ និង ពាក់កណ្តាលភូមិគ្រឹះ) | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - លំនៅឋានជាប់(ផ្ទះល្វែង និង ផ្ទះជាប់គ្នា) | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទប្រណីត | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទមធ្យម | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទធម្មតា | ផ្ទៃក្រឡាកម្រាល១៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

២- អគារពាណិជ្ជកម្ម រួមមាន៖

| | | |
|---|---|---|
| - ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងក្លឹបកម្សាន្ត | ផ្ទៃក្រឡាកម្រាល២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| | និងផ្ទៃក្រឡាកន្លែងរាំ១ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |

| | | |
|---|---|---|
| - ផ្សារទំនើប | ផ្ទៃក្រឡាកម្រាល៥០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ផ្សារ ឬ កន្លែងលក់ដូរ | ផ្ទៃក្រឡាកម្រាល៥០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារពាណិជ្ជកម្មផ្សេងៗ | ផ្ទៃក្រឡាកម្រាល៥០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

៣- អគារឧស្សាហកម្ម រួមមាន៖

| | |
|---|---|
| - អគាររោងចក្រ | ផ្ទៃក្រឡាកម្រាល២៥០ម២ ត្រូវមានចំណតរថយន្តតូច១កន្លែង និងក្រឡាផ្ទៃកម្រាល១២៥០ម២ត្រូវមានចំណតរថយន្តធំ១កន្លែង |
| - អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន | ផ្ទៃក្រឡាកម្រាល៤០០ម២ត្រូវមានចំណតរថយន្តតូច១កន្លែង និង ផ្ទៃក្រឡាកម្រាល២០០០ម២ត្រូវមានចំណតរថយន្តធំ១កន្លែង។ |

៤- អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖

| | | |
|---|---|---|
| - អគារគ្រឹះស្ថានឧត្តមសិក្សា | ផ្ទៃក្រឡាកម្រាល១០០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារគ្រឹះស្ថានមធ្យមសិក្សា | ផ្ទៃក្រឡាកម្រាល២០០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារគ្រឹះស្ថានបឋមសិក្សា | ផ្ទៃក្រឡាកម្រាល៣០០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - មជ្ឈមណ្ឌលកីឡា | ផ្ទៃក្រឡាកម្រាល១០០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

៥- អគារសុខភាព រួមមាន៖

| | | |
|---|---|---|
| - អគារមន្ទីរពេទ្យ | ផ្ទៃក្រឡាកម្រាល១០០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ក្លឹបហាត់ប្រាណនិងសុខភាព | ផ្ទៃក្រឡាកម្រាល១២០ម២ | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

៦- អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត រួមមាន៖

| | |
|---|---|
| - អគារមហោស្រព រោងភាពយន្ត សាលជួបជុំ និងពិធី | ផ្ទៃក្រឡាកម្រាល៣០ម២ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៣០០ម២ត្រូវមានចំណតរថយន្តធំ១កន្លែង។ |

៧- អគារសណ្ឋាគារនិងផ្ទះសំណាក់ រួមមាន៖

| | | |
|---|---|---|
| - អគារសណ្ឋាគារ | ចំនួនបន្ទប់៥បន្ទប់ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| | និងចំនួនបន្ទប់៣០បន្ទប់ | ត្រូវមានចំណតរថយន្តធំ១កន្លែង |
| - អគារផ្ទះសំណាក់ | ចំនួនបន្ទប់១០បន្ទប់ | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| | និងចំនួនបន្ទប់៣០បន្ទប់ | ត្រូវមានចំណតរថយន្តធំ១កន្លែង។ |

៨- អគារការិយាល័យសាធារណៈនិងការិយាល័យឯកជន រួមមាន៖

| | |
|---|---|
| - អគាររដ្ឋបាលនិងការិយាល័យឯកជន | ផ្ទៃក្រឡាកម្រាល ១០០ម២ ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

៩- ស្ថានីយប្រេងឥន្ធនៈ រួមមាន៖

| | |
|---|---|
| - ស្ថានីយប្រេងឥន្ធនៈ | ផ្ទៃក្រឡាកម្រាល១០ម២ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល១០០ម២ត្រូវមានចំណតរថយន្តធំ១កន្លែង។ |

១០- អគារការិយាល័យដឹកជញ្ជូន រួមមាន៖

| | |
|---|---|
| - អគារការិយាល័យដឹកជញ្ជូន | ផ្ទៃក្រឡាកម្រាល១០០ម២ ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម២ត្រូវមានចំណតរថយន្តធំ១កន្លែង។ |

១១- អគារផ្សេងៗរួមមាន៖

- អគារផ្សេងៗ ផ្ទៃក្រឡាកម្រាល១៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ដែលបានកំណត់ខាងលើនេះ ជាចំនួនអប្បបរមាដែលត្រូវមានជាចាំបាច់ សម្រាប់ការអភិវឌ្ឍនិងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតនេះត្រូវយកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ក្នុងករណីអគារបម្រើមុខងារចម្រុះ ការគណនាចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុប សម្រាប់អគារទាំងមូល។

ការរៀបចំចំណតយានយន្តនៅទីសាធារណៈនិងឯកជនត្រូវមានចំណតសម្រាប់ជនពិការនិងជនងាយរងគ្រោះ។

បទដ្ឋានចំណតយានយន្ត ទំហំចំណត និងលក្ខណៈបច្ចេកទេសសម្រាប់ចំណតក្នុងដីឡូត៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះបទដ្ឋានកំណត់ទីតាំងចំណតយានយន្តនិងទំហំចំណតសម្រាប់ចំណតសាធារណៈក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការចេញលិខិតអនុញ្ញាតសាងសង់ណាមួយចំពោះប្រភេទអគារខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិចំនួនចំណតអប្បបរមានៃមាត្រា៣៤នេះ។

**មាត្រា៣៨ .- ថ្មី**

គម្លាតចន្លោះរវាងមហាវិថីមួយទៅមហាវិថីមួយ ឬពីវិថីមួយទៅវិថីមួយ ឬពីផ្លូវមួយទៅផ្លូវមួយ និងទំហំផ្លូវនីមួយៗដូចមានចែងក្នុងមាត្រា៣៧ខាងលើ ត្រូវគោរពតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនិងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៥០ .- ថ្មី**

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី ត្រូវបានអនុវត្តក្នុងគោលដៅផ្លាស់ប្តូរប្រភេទនៃការប្រើប្រាស់ដី កែសម្រួលតំបន់ប្រើប្រាស់ដីឡើងវិញ ដើម្បីធ្វើការអភិវឌ្ឍទីក្រុង មានជាអាទិ៍ការបង្រួមក្បាលដីឬការបំបែកក្បាលដី ដោយត្រូវគោរពតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងធានាបាននូវបទដ្ឋានអប្បបរមានៃការប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ព្រមទាំងលក្ខខណ្ឌបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច។

១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវបានអនុវត្តដោយការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមមាត្រា៣៣នៃអនុក្រឹត្យនេះ។

១.២- គម្រោងបង្រួមក្បាលដី ត្រូវបានអនុវត្តដោយការបូកបញ្ចូលក្បាលដីដែលស្ថិតនៅជាប់គ្នាទាំងអស់ក្នុងក្របខ័ណ្ឌនៃគម្រោង ដើម្បីរៀបចំជាប្លង់ប្រើប្រាស់ដីសមាហរណកម្មមួយសម្រាប់ការអភិវឌ្ឍនិងការសាងសង់ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

១.៣- គម្រោងបំបែកក្បាលដីត្រូវបានអនុវត្តដោយការបំបែកក្បាលដីមួយជាដីឡូត៍បច្ចេកទេសច្រើនសម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

២- គម្រោងកែសម្រួលក្បាលដី ត្រូវបានអនុវត្តដោយការរៀបចំក្បាលដីឡើងវិញ ដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួមនិងការយល់ព្រមបរិច្ចាគដីពីម្ចាស់ដីឡូត៍ទាំងអស់ ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ ត្រូវបានអនុវត្តនៅតំបន់ណាមួយនៃទីក្រុង ក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនលទ្ធភាពប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាពនិងសោភណភាព តាមរយៈការផ្ទេរសិទ្ធិលើដីនិងអគារទៅជាសិទ្ធិលើផ្ទៃក្រឡាកម្រាលអគារថ្មីដែលមានតម្លៃស្មើនៅក្នុងគម្រោងនេះ ដោយមានការចូលរួមនិងយល់ព្រមពីម្ចាស់ដីឡូត៍ ឬតាមតម្រូវការនៃការអភិវឌ្ឍទីក្រុង ស្របតាមច្បាប់។

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី ត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែមនូវតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវមុខងាររបស់ទីក្រុងសម្រាប់ការរស់នៅ ការសម្រាកលំហែកម្សាន្ត ការមានការងារធ្វើ និងការធ្វើចរាចរប្រកបដោយសុវត្ថិភាពនិងសោភណភាព។

៥- គម្រោងអភិវឌ្ឍន៍លំនៅឋាន ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវសុខភាព ផាសុកភាព សោភណភាព និងសុខដុមរមណីយកម្មសម្រាប់ការស្នាក់នៅ ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ដល់ការស្នាក់នៅ។

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម ត្រូវបានអនុវត្តក្នុងគោលដៅធានាបាននូវការឯកភាព និងសុខដុមនីយកម្មសម្រាប់ឧស្សាហកម្ម ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗដល់សុខភាព។

៧- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥។ ការធ្វើប្លង់គោលនិងផែនការប្រើប្រាស់ដីសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ត្រូវតែធានាបាននូវបទដ្ឋានអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ព្រមទាំងធានាបាននូវការធ្វើសមាហរណកម្មនៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់នេះ ទៅនឹងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ឬផែនការថ្មីនៃទីក្រុង ខេត្ត តំបន់ និងជាតិ។

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែម ឬបង្កើតថ្មីនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើម្បីឲ្យឆ្លើយតបនឹងកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទីក្រុង ខេត្ត តំបន់ និងជាតិ។

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ត្រូវបានអនុវត្តក្នុងគោលដៅទាក់ទាញការវិនិយោគវិស័យទេសចរណ៍ និងលើកកម្ពស់គុណភាពសេវាទេសចរណ៍ ស្របតាមគោលនយោបាយ ទេសចរណ៍នៅកម្ពុជា។

១០-គម្រោងចែករំលែកដី ត្រូវបានអនុវត្តក្នុងគោលដៅកែលម្អស្ថានភាព លក្ខខណ្ឌរស់នៅ និងសោភណភាពនៃសហគមន៍ ឲ្យទទួលបានលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ សមស្រប។ គម្រោងចែករំលែកដី ត្រូវធ្វើឡើងដោយមានការឯកភាពពីម្ចាស់ដី និង/ឬ សហគមន៍ និងអ្នកវិនិយោគ ក្នុងការចែករំលែកផលប្រយោជន៍គ្នាទៅវិញទៅមក។

១១-គម្រោងអភិវឌ្ឍផ្សេងៗ ត្រូវបានអនុវត្តដើម្បីបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍទីក្រុង ក្នុងគោលបំណងធានាបាននូវសុខភាព ផាសុកភាព សោភណភាព និងសុខដុមនីយកម្មសម្រាប់ការស្នាក់នៅ។

**មាត្រា៦៦ ._ ថ្មី**

ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា៦៥ខាងលើ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតអភិវឌ្ឍ លិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ លិខិតបើកនិងបិទការដ្ឋាន។

**មាត្រា៧៤ ._ ថ្មី**

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលៈ

ក. មិនព្រមបញ្ឈប់ការដ្ឋានសាងសង់តាមបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចឬមិនប្រើប្រាស់សិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៦៨នៃអនុក្រឹត្យនេះ ឬ

ខ. រារាំងឬប្រកែកមិនព្រមឲ្យសមត្ថកិច្ចជំនាញចូលត្រួតពិនិត្យការដ្ឋានសាងសង់ ឬ

គ. ប្រកែកមិនព្រមផ្តល់ព័ត៌មានឬបង្ហាញលិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដល់សមត្ថកិច្ចជំនាញក្នុងពេលចុះពិនិត្យការដ្ឋានសំណង់ ឬ

ឃ. ប្រើប្រាស់មធ្យោបាយណាមួយដើម្បីជាឧបសគ្គដល់ការត្រួតពិនិត្យការដ្ឋានសំណង់របស់អង្គភាពជំនាញមានសមត្ថកិច្ច។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួនៈ

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោមៈ

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបវិជ្ជាជីវកម្មសាងសង់ឬវិញ្ញាបនបត្រអភិវឌ្ឍអចលនវត្ថុ
- បង្ខំឲ្យរុះរើនិងស្ថាបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

**មាត្រា៨២ ._ ថ្មី**

ចំណូលកម្រៃសេវាដូចមានចែងក្នុងមាត្រា៨១ខាងលើនេះ ត្រូវបែងចែកមួយផ្នែកចូលថវិកាជាតិ មួយផ្នែកសម្រាប់គាំទ្រការងារបច្ចេកទេសនគរូបនីយកម្មនិងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មួយផ្នែកទៀតសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

ការបែងចែកចំណូលបានមកពីកម្រៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

**មាត្រាពីរ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាទី ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៥
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ